ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០០១ សហវ.ក្រយ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ញាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងយុត្តិធម៌ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងយុត្តិធម៌ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងយុត្តិធម៌ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣** :

ក្រសួងយុត្តិធម៌ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥** :

ក្រសួងយុត្តិធម៌ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៦** :

ក្រសួងយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៧** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់ តាមរយៈប្រកាសរួម។

**ប្រការ ៨** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍានៈ**

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

**«ដើម្បីជូនជ្រាប»**
- ដូចប្រការ ៩ **«ដើម្បីមុខការ»**
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១០០១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងយុត្តិធម៌

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| **I. សេវាសាធារណៈស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រសួងយុត្តិធម៌** | | | | |
| 1 | ការចេញព្រឹត្តិបត្រថ្កោលទោសលេខ 3 | | | |
| 1.1 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិខ្មែរ ក្រៅពីសិស្ស និងនិស្សិត) | 30,000 | 20ថ្ងៃ | 3ខែ |
| | | 60,000 | 12ថ្ងៃ | 3ខែ |
| 1.2 | ព្រឹត្តិបត្រថ្កោលទោស( ជនជាតិខ្មែរជាសិស្ស ឬនិស្សិត ) | 10,000 | 20ថ្ងៃ | 3ខែ |
| | | 20,000 | 12ថ្ងៃ | 3ខែ |
| 1.3 | ព្រឹត្តិបត្រថ្កោលទោស (ជនជាតិបរទេស) | 250,000 | 20ថ្ងៃ | 3ខែ |
| | | 500,000 | 12ថ្ងៃ | 3ខែ |
| 1.4 | បកប្រែជាភាសាបរទេស( ព្រឹត្តិបត្រថ្កោលទោស ) | 40,000 | 20ថ្ងៃ | 3ខែ |
| | | 60,000 | 12ថ្ងៃ | 3ខែ |
| **II. សេវាសាធារណៈនៅតាមសាលាជម្រះក្តី** | | | | |
| 1 | ពន្ធដាក់ពាក្យបណ្តឹង( គិតតាមតម្លៃកម្មវត្ថុនៃបណ្តឹង ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ) | | | |
| 1.1 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃត្រឹម 10លានរៀល | 1% នៃតម្លៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1.2 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 10លាន ដល់ 100លានរៀល | (10លាន ×1%)+ (ភាគតម្លៃលើសពី 10លាន×0.7%) | | |
| 1.3 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 100លាន ដល់ 1000លានរៀល | (10លាន ×1%)+ (90លាន×0.7%)+ (ភាគតម្លៃលើសពី 100លាន×0.3%) | | |
| 1.4 | ពន្ធដាក់ពាក្យបណ្តឹង មានតម្លៃលើសពី 1000លានរៀល | (10លាន ×1%)+ (90លាន×0.7%)+ (900លាន×0.3%)+ (ភាគតម្លៃលើសពី 1000លាន×0.1%) | | |
| 2 | ពន្ធដាក់ពាក្យបណ្តឹងឧបាស្រ័យ | | | |
| 2.1 | ពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ | 1.5ដង នៃពន្ធដែលបានបង់រួចនៅសាលាដំបូង | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2.2 | ពន្ធដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូល | 2ដង នៃពន្ធដែលបានបង់រួចនៅសាលាដំបូង | | |
| 3 | ពន្ធដាក់ពាក្យបណ្តឹងជំនុំជម្រះសារជាថ្មី ( សាលាជម្រះក្តីគ្រប់ថ្នាក់ ) | 10,000 | | |
| 4 | ពន្ធដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន( សាលាជម្រះក្តីដំបូង ) | 1/2នៃប្រាក់ពន្ធដែលគណនាតាមតម្លៃនៃកម្មវត្ថុបណ្តឹង | | |
| 5 | ពន្ធដាក់ពាក្យសុំទៅតុលាការឱ្យសម្រេចសេចក្តី ក្រៅពីពន្ធទាំងឡាយដែលបានរៀបរាប់ខាងលើ ( មាន 17 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 1 នៃប្រកាសលេខ 28 កយ ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | 5,000 | | |
| 5.1 | ពាក្យប្តឹងជិតចិត្ត (មាត្រា 28) | 5,000 | | |
| 5.2 | ពាក្យសុំចូលរួមជួយអន្តរាគមន៍ ពាក្យសុំចូលរួមអន្តរាគមន៍ ក្នុងសហបណ្តឹង (មាត្រា 43, 49) | 5,000 | | |
| 5.3 | ពាក្យសុំឲ្យថែរក្សាការពារភស្តុតាងដែលធ្វើមុនពេលដាក់ពាក្យបណ្តឹង (មាត្រា 164, កថាខណ្ឌទី2) | 5,000 | | |
| 5.4 | ពាក្យប្តឹងទាស់ ( មាត្រា 204 ) | 5,000 | | |
| 5.5 | ពាក្យប្តឹងជំទាស់ (មាត្រា 301 ) | 5,000 | | |
| 5.6 | ពាក្យសុំតវ៉ាចំពោះការអនុវត្ត ( មាត្រា 344 ) | 5,000 | | |
| 5.7 | ពាក្យសុំឲ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ( មាត្រា 353 ) | 5,000 | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5.8 | ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ( មាត្រា 362 ) | 5,000 | | |
| 5.9 | ពាក្យសុំឲ្យផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ ( មាត្រា 366, 367, 369 ) | 5,000 | | |
| 5.1 | ពាក្យសុំឲ្យដីកាសម្រេចបង្គាប់ឲ្យប្រគល់( មាត្រា 390, 450, 459, 483 ) | 5,000 | | |
| 5.11 | ពាក្យសុំទាមទារឲ្យចែកចំណែក (មាត្រា 394, 409, 426 ) | 5,000 | | |
| 5.12 | ពាក្យសុំការចាត់ចែងការរក្សាការពារ ( មាត្រា 429 ) | 5,000 | | |
| 5.13 | ពាក្យសុំឲ្យលុបចោលនីតិវិធីលក់ដោយបង្ខំដោយដាក់ប្រាក់ធានា ( មាត្រា 461 ) | 5,000 | | |
| 5.14 | ពាក្យសុំការអនុញ្ញាតឲ្យនាវាធ្វើដំណើរ (មាត្រា 462 ) | 5,000 | | |
| 5.15 | ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ( មាត្រា 550 ) | 5,000 | | |
| 5.16 | ពាក្យសុំឲ្យផ្អាកការអនុវត្តរក្សាការពារ ( មាត្រា 551 ) | 5,000 | | |
| 5.17 | ពាក្យសុំឲ្យលុបចោលដីកាសម្រេចរក្សាការពារ ( មាត្រា 557, 558, 559) | 5,000 | | |
| 6 | ពន្ធដែលត្រូវបង់ដើម្បីធ្វើសកម្មភាព ក្រៅពីពន្ធដាក់ពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្ដីទាំង 17ខាងលើ ( មាន 4 ប្រភេទ បានចែងក្នុងឧបសម្ព័ន្ធ 2 ក្នុងប្រកាសលេខ 28 កយ.ប្រក/07 របស់ក្រសួងយុត្តិធម៌ ) | | | |
| 6.1 | ការទាមទារមើល ឬការទាមទារថតចម្លងសំណុំរឿង ។ ប៉ុន្តែក្នុងករណី ដែលភាគីទាមទារនៅពេលដែលរឿងក្ដីកំពុងចាត់ការមិនតម្រូវឲ្យបង់ទេ ។ ចំពោះការចំណាយក្នុងការថតចម្លងឯកសារសំណុំរឿង ជាបន្ទុករបស់អ្នកទាមទារ ។ ( មាត្រា 258, 378, 538 ) | 5,000 ក្នុងមួយដង | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 6.2 | ការប្រគល់ឯកសារចម្លងយថាភូត ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ( មាត្រា 258, 378, 538 ) | 5,000 ក្នុងឯកសារ 1 ឈុត | | |
| 6.3 | ការប្រគល់នូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេច ( មាត្រា 258, 378, 355 កឋាខណ្ឌ 2 ជាអាទិ៍ ) | 5,000 ក្នុងឯកសារ 1 ឈុត | | |
| 6.4 | ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត ( មាត្រា 355 ជាអាទិ៍ ) | 5,000 | | |
| 7 | ប្រាក់ពិន័យផ្សេងៗ ដែលទទួលបានពីការសម្រេចរបស់តុលាការ | តាមសេចក្តីសម្រេចរបស់តុលាការ | | |

**បញ្ជាក់:** ចំពោះរូបមន្តនៃតម្លៃសេវាលើពន្ធដាក់ពាក្យបណ្តឹងគ្រប់ប្រភេទ ដែលចែងក្នុងតារាងឧបសម្ព័ន្ធនេះ ត្រូវបានធ្វើការគណនាចេញជាចំនួនទឹកប្រាក់រួចជាស្រេចទៅតាមទំហំតម្លៃកម្មវត្ថុនៃបណ្តឹង សម្រាប់អ្នកប្រមូលចំណូលនៅតាមសាលាជម្រះក្តីប្រើជាមូលដ្ឋាន ដូចមានរាយលម្អិតនៅក្នុង«**តារាងនៃពន្ធដាក់ពាក្យបណ្តឹងពន្ធដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងពន្ធដាក់ពាក្យបណ្តឹងសាទុក្ខ តាមតម្លៃកម្មវត្ថុនៃបណ្តឹង**» ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ និងមានជំនួយឧបត្ថម្ភដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។